**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតឃុំគ្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត**ឃុំគ្រញូងសែនជ័យ** នៃស្រុកស្នួល ខេត្តក្រចេះ ដោយកាត់យកភូមិចំនួន០៣ នៃឃុំខ្សឹម គឺភូមិគ្រញូងសែនជ័យ ភូមិវាលបីចក្រីហេង និងភូមិជ្រោះជ្រៅពោធិ៍សាល និងភូមិចំនួន០១ នៃឃុំឃ្សឹម គឺភូមិគ្រញូងសែនជ័យខាងជើង។

ឃុំគ្រញូងសែនជ័យ មានភូមិចំនួន០៤ គឺភូមិគ្រញូងសែនជ័យ ភូមិវាលបីចក្រីហេង ភូមិជ្រោះជ្រៅពោធិ៍សាល និងភូមិគ្រញូងសែនជ័យខាងជើង។

ព្រំប្រទល់រដ្ឋបាលនៃឃុំគ្រញូងសែនជ័យ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

ទីតាំងសាលាឃុំគ្រញូងសែនជ័យ ស្ថិតនៅក្នុងភូមិគ្រញូងសែនជ័យខាងជើង។

**មាត្រា ៤.-**

ការបង្កើត**ឃុំគ្រញូងសែនជ័យ** ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី៤ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាឃុំ២ធ្នូ ត្រូវបន្តគ្រប់គ្រងភូមិចំនួន០៣ គឺភូមិគ្រញូងសែនជ័យ ភូមិវាលបីចក្រីហេង និងភូមិជ្រោះជ្រៅ ពោធិ៍សាល រហូតដល់មានក្រុមប្រឹក្សាឃុំគ្រញូងសែនជ័យមកជំនួស។

ក្រុមប្រឹក្សាឃុំឃ្សឹម ត្រូវបន្តគ្រប់គ្រងភូមិចំនួន០១ គឺភូមិគ្រញូងសែនជ័យខាងជើង រហូតដល់មានក្រុមប្រឹក្សាឃុំគ្រញូងសែនជ័យមកជំនួស។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំគ្រញូងសែនជ័យ ត្រូវអនុលោមទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាខេត្តក្រចេះ គណៈអភិបាលខេត្តក្រចេះ ក្រុមប្រឹក្សាស្រុកស្នួល គណៈអភិបាលស្រុកស្នួល ក្រុមប្រឹក្សាឃុំ២ធ្នូ ក្រុមប្រឹក្សាឃុំឃ្សឹម និងក្រុមប្រឹក្សាឃុំគ្រញូងសែនជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
ខេត្តក្រចេះ

ផែនទីព្រំប្រទល់រដ្ឋបាលឃុំបង្កើតថ្មីឈ្មោះថា ឃុំក្បាលដំរីសែនជ័យ ដែលបំបែកចេញពីឃុំ២ធ្នូ និងឃុំឃ្សឹម ស្ថិតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ

ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យ........ថ្ងៃទី..........ខែ..........ឆ្នាំ..........




| ទំណុចនិយាមការគោលព្រំប្រទល់ឃុំបង្កើតថ្មី | | |
|---|---|---|
| ID | X | Y |
| 1 | 694881 | 1339953 |
| 2 | 681543 | 1324851 |
| 3 | 681581 | 1330323 |
| 4 | 679571 | 1330285 |
| 5 | 670581 | 1338323 |
| 6 | 670581 | 1340923 |
| 7 | 669583 | 1340828 |
| 8 | 669578 | 1345138 |
| 9 | 679969 | 1345885 |
| 10 | 679938 | 1360073 |

លេខ.......
បានឃើញ និងពិនិត្យត្រឹមត្រូវ
ក្រចេះ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីខេត្ត

លេខ.......
បានឃើញ និងពិនិត្យត្រឹមត្រូវ
ស្នួល, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
អភិបាលស្រុក ស្នួល

លេខ.......
បានឃើញ និងពិនិត្យត្រឹមត្រូវ
ស្នួល, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងភូមិបាលស្រុកស្នួល

លេខ.......
បានពិនិត្យត្រឹមត្រូវ
២ធ្នូ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
មេឃុំ

លេខ.......
បានពិនិត្យត្រឹមត្រូវ
ឃ្សឹម, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
មេឃុំ

គូរដោយ
ក្រចេះ, ថ្ងៃទី...... ខែ...... ឆ្នាំ ២០១៦
សេង សុគ័ន្ធ

លេខ.......
បានឃើញ និង យល់ព្រម
រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

លេខ.......
បានឃើញ និង យល់ព្រម
ក្រចេះ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៦
អភិបាលខេត្ត